# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ
## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងឱកាសប្រារព្ធបើកសន្និសីទ
## ស្តីពីការបង្កើតបរិស្ថានគោលនយោបាយហិរញ្ញប្បទានជនបទ និងក្របខ័ណ្ឌបទប្បញ្ញត្តិ
ខេត្ត កំពង់ចាម ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧

សូមគោរព :

- ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី
- លោកស្រី Jovita M. Corpuz តំណាង APRACA
- លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ជាទីស្នេហា

ថ្ងៃនេះ ជាទិវាមួយដ៏ឧឡារិកដែលធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និសីទស្តីពី ការបង្កើតបរិស្ថានគោលនយោបាយហិរញ្ញប្បទានជនបទ និងក្របខ័ណ្ឌបទប្បញ្ញត្តិ នៅទឹកដីខេត្តកំពង់ចាម ដែលជាតំបន់កសិ-ឧស្សាហកម្មផង និងជារមណីយដ្ឋានទេសចរណ៍នៃប្រទេសកម្ពុជាយើងផង ដោយមានកិច្ចសហការណ៍ឧបត្ថម្ភពីសមាគមឥណទានជនបទប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (APRACA)។ ខ្ញុំសូមសំដែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមាន លោកស្រី Jovita M. Corpuz តំណាងសមាគម ឥណទានជនបទប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាភ្ញៀវកិត្តិយស និងជាតំណាងអាជ្ញាធរដែនដី មន្ទីរ-អង្គភាពនៅជុំវិញខេត្ត ធនាគារពាណិជ្ជ ប្រតិបត្តិករ មីក្រូហិរញ្ញវត្ថុ និង អង្គការក្រៅរដ្ឋាភិបាល នៅក្នុងភូមិភាគដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមក្នុងសន្និសីទ ក្នុងខណៈ ពេលនេះ ។ វត្តមានដ៏វិសេសវិសាលរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ញុំាងឱ្យពិធីនេះ មានដំណើរការកាន់តែមានភាពអធិកអធម មានអត្ថន័យយ៉ាងជ្រាលជ្រៅ មានភាពសប្បាយរីករាយ និងបានបង្ហាញ ពីកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទថែមទៀត ។

តាមរយៈចំណាប់អារម្មណ៏របស់ ឯកឧត្តម **ឈិត សុខុន** អភិបាលរងខេត្តកំពង់ចាម ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអាជ្ញាធរខេត្តកំពង់ចាម ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អ និងបង្កបរិយាកាសល្អដល់កិច្ចដំណើរការគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅទូទាំងខេត្តកំពង់ចាម ក៏ដូចជានៅក្នុងតំបន់ទាំងមូលផងដែរ ។ ខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះ ឯកឧត្តម **យឹម សុខុម** អភិបាលរងខេត្តព្រៃវែង ឯកឧត្តម **ប្រាក់ សារ៉ុធ**

អភិបាលរងខេត្តក្រចេះ ឯកឧត្តម **ណាំ ទុំ** អភិបាលខេត្តកំពង់ធំ ឯកឧត្តម **ងួន ប៉ែន** អភិបាលរងខេត្តស្វាយរៀង និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ដែលបានចូលរួម និងបានផ្តល់កិច្ចសហប្រតិបត្តិការល្អ ក្នុងការធ្វើឱ្យសកម្មភាពមីក្រូហិរញ្ញវត្ថុបានប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាទីមេត្រី**

គោលបំណងនៃសន្និសីទថ្ងៃនេះ រៀបចំឡើងដើម្បីផ្សព្វផ្សាយពីដំណើរការវិវត្តន៍រីកចំរើននៃមីក្រូហិរញ្ញវត្ថុកម្ពុជា និងឱ្យសាធារណជនបានជ្រួតជ្រាបអំពី :

១- ភាពជឿនលឿននៃការអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន**

២- តួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងវិស័យមីក្រូហិរញ្ញវត្ថុ

៣- វេទិកាសាធារណៈសំរាប់ផ្លាស់ប្តូរយោបល់ និងបទពិសោធន៍រវាងអាជ្ញាធរអាណាព្យាបាល និង ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ

៤-ការផ្លាស់ប្តូរបទពិសោធន៍ជាមួយ APRACA ។

## I/- ភាពជឿនលឿននៃការអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេច នាយករដ្ឋមន្ត្រី ហ៊ុន សែន

បន្ទាប់ពីរាជរដ្ឋាភិបាលដែលមានសម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ជាប្រមុខ បានប្រកាសប្រសិទ្ធិនាមយក **ឆ្នាំ២០០៦ ជាឆ្នាំមីក្រូហិរញ្ញវត្ថុកម្ពុជា** និងបានដាក់ចេញនូវអនុសាសន៍ចំនួន ៦ ចំនុច សំរាប់ឱ្យធនាគារជាតិនៃកម្ពុជាដែលជាអាជ្ញាធរអាណាព្យាបាល និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុអនុវត្តតាមរួចមក ឃើញថា បច្ចុប្បន្នវិស័យនេះមានការរីកចំរើនយ៉ាងខ្លាំង និងទទួលបានការគាំទ្រពីមជ្ឈដ្ឋានក្នុងនិងក្រៅប្រទេសថា **ជាកូនសោរសំរាប់ចាក់ទម្លាយ ភាពក្រីក្ររបស់ប្រជាជនកម្ពុជា** ។

លទ្ធផលនៃការរីកចំរើនទាំងនេះ អាចឆ្លុះបញ្ចាំងតាមរយៈសមិទ្ធផលដូចខាងក្រោមនេះ :

១) - បច្ចុប្បន្ន ប្រព័ន្ធធនាគារនៅកម្ពុជាមានការចំរើនទាំងវិសាលភាពនិងទំហំសកម្មភាព ហើយបានចូលរួមចំណែកកាន់តែច្រើនឡើងៗក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ជាក់ស្តែង តាមរយៈអន្តរការិយកម្មធនាគារ វិនិយោគិនអាចប្រមូលទុនក្នុងស្រុកបន្ថែមប្រមាណ ៥០០ លានដុល្លារសំរាប់រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិក្នុង ឆ្នាំ២០០៦ កន្លងមកនេះ ។ ចំពោះផ្នែកវិសាលភាព ចំនួនធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការកើនឡើង ចំណែកឯទំហំសកម្មភាពវិញ ទ្រព្យសកម្មសរុបកើនឡើង ៤២,៣២% ប្រាក់បញ្ញើកើន ៤៩,០១% និងឥណទានធនាគារពាណិជ្ជចំពោះវិស័យឯកជនកើន ៤៧,០៥% ។ ការវិវត្តជាវិជ្ជមាននេះ គួបផ្សំជាមួយនឹងការអនុវត្តវិធានការប្រុងប្រយ័ត្ន បានធ្វើឱ្យឥណទានមិនដំណើរការ (NPL) ថយចុះជាលំដាប់រហូតដល់ ៦.២% នៅឆ្នាំ២០០៦ ។

អនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដែលបានប្រើប្រាស់ប្រព័ន្ធធនាគារសំរាប់ធ្វើការប្រមូលនិងទទួលការបង់ពន្ធគ្រប់ប្រភេទ និងសំរាប់បើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទនោះ បានធ្វើឱ្យជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារកាន់តែកើនឡើង មានភាពរឹងមាំជាលំដាប់ និងទទួលបានការគាំទ្រពីសហគមន៍អន្តរជាតិផងដែរ ។

២) - ចំពោះវិស័យមីក្រូហិរញ្ញវត្ថុ នៅឆ្នាំ២០០៦ មានប្រជាពលរដ្ឋបានទទួលឥណទានចំនួន ៣៧៤ ពាន់លានរៀល និងមានអតិថិជនចំនួនជាង ៤៧១ ពាន់គ្រួសារ បានទទួលសេវាមីក្រូហិរញ្ញវត្ថុ ។ បើគិតត្រឹមឆមាសទី១ ឆ្នាំ២០០៧ នេះ ឥណទានរបស់មីក្រូហិរញ្ញវត្ថុបានកើនដល់ ៤៦៦ ពាន់លានរៀល បើគិតជាភាគរយមានកើនឡើងចំនួន ២៤.៣% និងមានអតិថិជនរហូតដល់ ៥១៩ ពាន់គ្រួសារ ។ ភាពជឿនលឿននេះ បញ្ជាក់ឱ្យឃើញថាប្រជាពលរដ្ឋកម្ពុជាមានការយល់ ដឹងប្រសើរពីសារៈសំខាន់នៃសេវាមីក្រូហិរញ្ញវត្ថុ និងវប្បធម៌ឥណទាន ។

៣) - កំរិតជីវភាពរបស់ប្រជាជននៅតាមជនបទមានការរីកចំរើនគួរឱ្យកត់សំគាល់ និងរស់នៅប្រកបដោយក្តីសង្ឃឹម និងមានភាពពិតប្រាកដក្នុងជីវិតរបស់ខ្លួន ។ ជាក់ស្តែង អត្រានៃភាពក្រីក្រ បានថយចុះមកត្រឹម ៣៥% នៅឆ្នាំ២០០៧នេះ ។ យើងសង្ឃឹមថា អត្រានេះនឹងបន្តថយមកត្រឹម១៥% បន្ថែមទៀត នៅឆ្នាំ២០១៥ ស្របតាមគោលដៅអភិវឌ្ឍន៍សហវត្សរបស់រាជរដ្ឋាភិបាល ។

៤) - ដោយសារវិស័យធនាគារផ្តោតប្រតិបត្តិការតែនៅទីក្រុង មិនអាចជួយដោះស្រាយតម្រូវការរបស់ប្រជាពលរដ្ឋក្រីក្រនៅជនបទបានក្នុងការប្រើប្រាស់សំរាប់សន្សំទ្រព្យសម្បត្តិ និងអភិវឌ្ឍមីក្រូសហគ្រាសបានឡើយ ដូច្នេះ មានតែវិស័យមីក្រូហិរញ្ញវត្ថុទេ ដែលអាចបំរើសេចក្តីត្រូវការរបស់បងប្អូនប្រជាពលរដ្ឋនៅតាមជនបទឱ្យទទួលបានឥណទានខ្នាតតូចយកទៅប្រកបមុខរបរចិញ្ចឹមជីវិតរបស់ខ្លួនប្រចាំថ្ងៃបាន ។

៥) - ក្របខ័ណ្ឌច្បាប់ត្រូវបានពង្រឹងឱ្យស្របតាមយន្តការទីផ្សារ ពោលគឺមិនឱ្យតឹងតែងពេក និងធូរលុងពេក ហើយហេដ្ឋារចនាសម្ព័ន្ធមីក្រូហិរញ្ញវត្ថុ ត្រូវបានពង្រឹងនិងពង្រីកដល់ជនបទ ដើម្បីបង្កលទ្ធភាពឱ្យប្រជាពលរដ្ឋក្រីក្រទទួលបានឥណទានខ្នាតតូចយកទៅប្រើប្រាស់ប្រកបមុខរបរចិញ្ចឹមជីវិតរបស់ខ្លួន ។

៦) - បច្ចុប្បន្ន យើងមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១៧ ដែលបានទទួលអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការពីធនាគារជាតិនៃកម្ពុជាឱ្យធ្វើប្រតិបត្តិការតាមច្បាប់ និងមានប្រតិបត្តិករមីក្រូហិរញ្ញវត្ថុជនបទចំនួន ២៦ ដែលបានចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា ។ លើសពីនេះ គឺមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនបានប្រែក្លាយទៅជាធនាគារឯកទេស ឬធនាគារពាណិជ្ជ ដោយសារតែការរីកចំរើននៃប្រតិបត្តិការរបស់ខ្លួន ។

## II/. តួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងវិស័យមីក្រូហិរញ្ញវត្ថុ :

ដោយសារកន្លងមក យើងសង្កេតឃើញនៅមានប្រជាពលរដ្ឋយើងភាគច្រើន នៅតែប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុក្រៅផ្លូវការ ប្រឈមនឹងកំរិតហានិភ័យខ្ពស់ និងកម្រៃការប្រាក់ខ្ពស់ម្យ៉ាង និងម្យ៉ាងទៀត ទស្សនៈ

វិស័យនៃការផ្តល់សេវាហិរញ្ញវត្ថុឱ្យបានដល់ដៃប្រជាជននៅតាមជនបទ គឺជាគំនិតផ្តួចផ្តើមរបស់គ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុ និងអង្គការក្រៅរដ្ឋាភិបាលតែប៉ុណ្ណោះ ហើយធនាគារពាណិជ្ជមានតែនៅទីក្រុង ដូច្នេះ ទើបអាជ្ញាធររៀបចំឱ្យមានបរិស្ថានគោលនយោបាយហិរញ្ញប្បទានជនបទ ដែលជាយន្តការបន្ថែមរបស់អាជ្ញាធរក្នុងការជំរុញឱ្យសេវាមីក្រូហិរញ្ញវត្ថុជនបទកាន់តែមានភាពសំបូរបែប ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ ដើម្បី បង្កើនកំរិតជីវភាពរស់នៅរបស់ខ្លួន ។

ធនាគារជាតិនៃកម្ពុជា តាងនាមឱ្យរាជរដ្ឋាភិបាលតែងតែគាំទ្រ និងលើកទឹកចិត្តជានិច្ចចំពោះការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ តាមរយៈការបង្កើតគោលនយោបាយ និងការបង្កបរិស្ថានអំណោយផលដល់ការរីកលូតលាស់វិស័យនេះ ជាពិសេសការលូតលាស់ផ្នែកគ្រឹះស្ថាន ដោយបង្កលក្ខណៈងាយស្រួលដល់អង្គការក្រៅរដ្ឋាភិបាលប្រែក្លាយទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ។ ក្រៅពីការលើកទឹកចិត្តជាគោលនយោបាយការបង្កបរិស្ថានអំណោយផលផ្នែករចនាសម្ព័ន្ធក៏ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាផងដែរ ។ ប្រព័ន្ធផ្លូវជាតិផ្លូវលំជនបទ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដទៃទៀត ត្រូវបានស្ថាបនានិងកែលំអកាន់តែច្រើនឡើង ចូលជ្រៅទៅកាន់តំបន់ឆ្ងាយៗដាច់ស្រយាល ដើម្បីសំរួលនិងបង្កភាពងាយស្រួលដល់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ចូលទៅផ្តល់សេវាដោយមានសោហ៊ុយទាប និងអាចកាត់បន្ថយអត្រាការប្រាក់បានមួយកំរិតផងដែរ ។

ដើម្បីលើកស្ទួយសេវាហិរញ្ញវត្ថុនៅជនបទ ឱ្យកាន់តែមានសណ្តាប់ធ្នាប់ គឺតម្រូវឱ្យអង្គការក្រៅរដ្ឋាភិបាលដែលជាអ្នកផ្គត់ផ្គង់សេវា ចាំបាច់ត្រូវមានអាជ្ញាប័ណ្ណ ឬចុះបញ្ជីជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីធ្វើប្រតិបត្តិការក្រោមវិធានបទប្បញ្ញត្តិច្បាប់ និងការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ។ គោលបំណងនៃបទបញ្ញានេះ គឺមិនមែនដើម្បីកម្រិតនូវសកម្មភាពរបស់ពួកគេទេ ផ្ទុយទៅវិញ ដើម្បីលើកស្ទួយដល់គ្រឹះស្ថាន ក្នុងការជួយកេណ្ឌប្រមូលប្រាក់សន្សំនិងប្រាក់បញ្ញើពីសមាជិករបស់ខ្លួន ក៏ដូចជាពីសាធារណជន និងអាចទទួលបានឥណទានពីប្រភពក្នុងនិងក្រៅប្រទេសមក ដើម្បីពង្រីកសកម្មភាពរបស់ខ្លួនផងដែរ ។

ម្យ៉ាងទៀត សកម្មភាពមីក្រូហិរញ្ញវត្ថុ ក៏ដូចជាសកម្មភាពហិរញ្ញវត្ថុដទៃទៀត ត្រូវតែមានបទបញ្ញាមួយសមស្រប ដើម្បីសំរួលដល់សកម្មភាពរបស់គ្រឹះស្ថាន ។ ប្រសិនបើ បទបញ្ញាមានការរិតត្បិតខ្លាំងពេក នឹងនាំឱ្យមានការរាំងស្ទះដល់ប្រតិបត្តិការ ក៏ដូចជាការដាក់បន្ទុកបន្ថែមដល់គ្រឹះស្ថានទាំងនោះ ។ ដើម្បីធានាឱ្យការអនុវត្តច្បាប់ និងបទបញ្ញាប្រុងប្រយ័ត្ន ធនាគារជាតិនៃកម្ពុជាបានធ្វើការត្រួតពិនិត្យជាប្រចាំ ទាំងការត្រួតពិនិត្យលើឯកសារនិងការត្រួតពិនិត្យដល់ទីកន្លែង ។ ក្រៅពីសកម្មភាពត្រួតពិនិត្យទាំងនេះ ធនាគារជាតិនៃកម្ពុជាបានជំរុញឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបង្កើតនូវសមាគមវិជ្ជាជីវៈមួយ ដើម្បីអាចទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជា ឬគ្រឹះស្ថានដទៃទៀត ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

## III/- វេទិកាសាធារណៈសំរាប់ផ្លាស់ប្តូរយោបល់ និងបទពិសោធន៍រវាងអាជ្ញាធរអាណាព្យាបាល និង ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ

អង្គសន្និសីទថ្ងៃនេះ មិនត្រឹមតែលើកឡើងពីភាពជឿនលឿននៃវិស័យមីក្រូហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកយកបញ្ហាប្រឈមចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការគៀងគរប្រាក់សញ្ច័យសំរាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិ ភ្នាក់ងារប្រមូលប្រាក់សន្សំនិងផ្តល់ឥណទានដល់ពលរដ្ឋក្រីក្រ ដើម្បីយកទៅបង្កបង្កើនផលប្រកបអាជីវកម្ម ការធ្វើអន្តរការិយកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងតួនាទីរបស់អាជ្ញាធរក្នុងការគាំទ្រប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ មកពិភាក្សាផងដែរ ដើម្បីរិះរកដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងឡាយ សំដៅធ្វើឱ្យប្រតិបត្តិការមីក្រូហិរញ្ញវត្ថុប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពទ្វេឡើង ។

ខ្ញុំសង្ឃឹមថា អង្គសន្និសីទរបស់យើងរយៈពេលមួយថ្ងៃនេះ នឹងទទួលបាននូវលទ្ធផលជាផ្លែផ្កា អាចជួយដោះស្រាយនូវរាល់បញ្ហាប្រឈមទាំងឡាយ ដែលអាជ្ញាធរ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុជួបប្រទះ សំដៅធ្វើឱ្យប្រតិបត្តិការមីក្រូហិរញ្ញវត្ថុប្រព្រឹត្តទៅដោយរលូន និងមានផលិតភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

## IV/- ការផ្លាស់ប្តូរបទពិសោធន៍ជាមួយ APRACA

APRACA គឺជាសមាគមឥណទានកសិកម្មជនបទប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ត្រូវបានបង្កើតឡើងនៅទសវត្សឆ្នាំ ១៩៧០ មានសមាជិកចំនួន ២៦ ប្រទេស ក្នុងនោះកម្ពុជាបានក្លាយជាសមាជិកនៅ ឆ្នាំ២០០០ ។ APRACA បង្កើតឡើង ហើយបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់កិច្ចសហប្រតិបត្តិការ ពិគ្រោះយោបល់ ផ្លាស់ប្តូរអ្នកជំនាញការបច្ចេកទេស សំរបសំរួលកម្មវិធីបណ្តុះបណ្តាល និងសំរបសំរួលគំរោងជំនួយហិរញ្ញវត្ថុជនបទ រវាងប្រទេសជាសមាជិកនិងម្ចាស់ជំនួយ ក្នុងបំណងធ្វើយ៉ាងណាឱ្យការអភិវឌ្ឍវិស័យកសិកម្មជនបទ ប្រព្រឹត្តទៅដោយរលូន មានសុវត្ថិភាព និងផលិតភាព ។

បទពិសោធន៍ដែល APRACA ធ្លាប់មានកន្លងមក បានជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទនៃប្រទេសជាសមាជិកប្រែប្រួលជាវិជ្ជមាន ។ បទពិសោធន៍ទាំងនេះ មានសារៈសំខាន់ចំពោះប្រជាជនកម្ពុជាណាស់ ដូច្នេះ ខ្ញុំសូមអញ្ជើញតំណាង APRACA ចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់ បទពិសោធន៍ និងផ្តល់អនុសាសន៍ផ្សេងៗ ដើម្បីឱ្យអង្គសន្និសីទយើងយកទៅអនុវត្តក្របដោយផលិតភាព ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាទីស្នេហា**

ជាថ្មីម្តងទៀត ឆ្លៀតឱកាសនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរដល់អ្នកប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុទាំងអស់ដែលបានបង្ហាញនូវភាពទទួលខុសត្រូវក្នុងការខ្ចី និងសងមកវិញទាន់ពេល ជាពិសេស អ្នកខ្ចីជាស្ត្រី ត្រូវបានគេទទួលស្គាល់ថា មានអត្រានៃការទូទាត់សងវិញខ្ពស់ ។ អ្នកខ្ចីភាគច្រើនដែលបានខ្ចីឥណទានទៅប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព គឺការខ្ចីយកទៅប្រកបរបរកសិកម្ម និងអាជីវកម្មខ្នាតតូច ។ ប្រការនេះ នឹងរួមចំណែកបង្កើនជីវភាពប្រចាំថ្ងៃកាន់តែប្រសើរឡើង ។ កត្តាទាំងនេះ ជាវប្បធម៌ឥណទានដែលបានឆ្លុះបញ្ចាំងឱ្យឃើញនូវការយល់កាន់តែច្បាស់របស់ប្រជាជនយើង ក្នុងការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុ ។ ពួកគាត់ក៏បានយល់កាន់តែច្បាស់ផងដែរនូវអត្ថន័យនៃកិច្ចសន្យាឥណទានដែល គាត់បានធ្វើ ហើយត្រូវតែគោរពតាម ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាដែលបានចូលរួមសន្និសីទនេះ ឱ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបើក **សន្និសីទស្តីពីការបង្កើតបរិស្ថានគោលនយោបាយហិរញ្ញប្បទានជនបទ និងក្របខ័ណ្ឌបទប្បញ្ញត្តិ** ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**